យប់នោះខ្ញុំបាននិយាយរឿងជាច្រើនជាមួយនាង។ ខ្ញុំប្រាប់នាងថា បច្ចុប្បន្ននេះ មានមនុស្សជាច្រើនត្រូវបានបាត់បង់ឱកាសរបស់ពួកគេ។ វិបត្តិនៃភាពក្រីក្រនិងជំងឺឆ្លង ធ្វើឱ្យការរស់នៅរបស់កុមារជាច្រើនកាន់តែលំបាកជាងជំនាន់យើងនៅភូមិជើងចាបពីមុនទៅទៀត។

យើងធ្លាប់ជាក្មេងកំព្រាតស៊ូលំបាកវេទនា ស្គាល់ច្បាស់ថា តើការរឹងមាំមានតម្លៃកម្រិតណាសម្រាប់ជាគំរូដល់អ្នកជំនាន់ក្រោយក្នុងការតស៊ូ ហេតុអ្វីមកបណ្ដោយខ្លួនឯងឱ្យធ្លាក់ទៅក្នុងគ្រឿងស្រវឹងអូទីន្ទបាន?

ម្ដាយខ្ញុំធ្លាក់ខ្លួនក្រិនថ្លើម ខ្សោយបេះដូង និងមានរោគទឹកនោមផ្អែមរ៉ាំរ៉ៃរស់លំបាកវេទនាដល់សព្វថ្ងៃ ក៏ព្រោះតែការងារឃោសនាស្រាបៀរជាង១០ឆ្នាំរកប្រាក់ចិញ្ចឹមកូនប្រុស គាត់ត្រូវគេបញ្ឆោត ឱ្យផឹករាល់យប់ ចំណែកនាង ខ្ញុំសួរនាងថា ខណៈនាងអាចជ្រើសរើសបាន ហេតុអ្វីនាងជ្រើសរើសយកសុរា?

រហូតដល់ម៉ោងជិតប្រាំភ្លឺ គឺរយៈពេលជិតពីរម៉ោងកន្លងទៅ ដែលខ្ញុំនៅអង្គុយប្រដៅប្រដៅនាងរហូតខណៈនាងគេងស្ប៉ាប់ផ្ងើមិនឮលើគ្រែរបស់ខ្ញុំ លើគ្រែកម្សត់តូចមួយ ផ្ទុយមេឃនិងដី នឹងគ្រែមានតម្លៃប្រណីតនៅផ្ទះប្ដីបណ្ឌិតរបស់នាង។ ខ្ញុំនិយាយហើយនិយាយទៀត ឱ្យនាងចោលស្រា ចោលភាពទន់ជ្រាយ មើលថែសុខភាពឡើងវិញ ហើយព្យាយាមប្រើជីវិតសាជាថ្មីត្រូវចេះរស់នៅជាមួយអនាគត មិនមែនអតីតកាលនោះឡើយ។

ដ្បិតតែបេះដូងទាំងពីរនេះសែនវេទនាព្រោះពាក្យ «នៅស្រលាញ់ និងមិនបានដូចបំណង» ក៏ពួកយើងមិនបានធ្វើអ្វីខុសសីលធម៌ជាមួយគ្នាឡើយ ព្រោះគេជាមនុស្សមានប្ដីទៅហើយ ណាមួយខ្ញុំប្រឆាំងជានិច្ចនឹងពាក្យដែលថា អ្នកក្រដូចខ្ញុំ ជាជំពូកមនុស្សអសីលធម៌ ស្រេកឃ្លានប្រាក់និងអនាចាររឿងស្នេហា។

ក្នុងជីវិតរបស់ខ្ញុំ មិនថាអ្នកណាគិតអំពីខ្ញុំថាបែបណា រឿងដែលខ្ញុំនៅតែបន្តឈរខែងរ៉ែងមិនចុះចាញ់ទណ្ឌកម្មបោកប្រាស់ ទ្រុស្ដ រមិលគុណដែលមេឃនេះទម្លាក់មកលើស្មាខ្ញុំ ក៏ព្រោះខ្ញុំមានអ្វីមួយពីកំណើត គឺខ្ញុំតែងគោរពខ្លួនឯង។

ខ្ញុំជាមនុស្សប្រុសដើមទ្រូង៥ហត្ថពិតប្រាកដម្នាក់ ហើយរឿងនេះនឹងបន្តរហូតដល់ថ្ងៃមួយដែលខ្ញុំចូលរណ្ដៅលែងឈរជំទែងលើជើងទាំងពីរបានទៀត។

ស្នេហា ការបបោសអង្អែល គ្រប់ស្នាមថើបរវាងពីរនាក់យើងកាលពីអតីតកាល បានត្រូវខ្ញុំកាយដីលុបចោលទុកជាផ្នូរ នៅក្រោយការរៀបការរបស់គេជាមួយអាម៉ាចទៅហើយ ទោះនាងតែងបង្ហាញ

ថា ចង់បានការថ្នាក់ថ្នមនោះទៀត តែខ្ញុំតែងតែដើរតួជាមនុស្សគ្មានវិញ្ញាណ និងគ្មានបេះដូងនៅចំពោះមុខនាង។

មនុស្សដែលខ្ញុំធ្លាប់តាំងចិត្តទុកថាជាប្អូនកម្សត់ ក្រោយមកជាសង្សារ ហើយចុងក្រោយក្លាយជាប្អូនថ្លៃ ពេលនេះគេងលក់ស្កប់ស្កល់ហាក់មានសេចក្តីសុខមិនព្រួយភ័យអ្វីទាំងអស់ នៅលើគ្រែអ្នកក្រដូចខ្ញុំ។

ខ្ញុំទប់ចិត្តមិនបាននឹងការអាណិតអាសូរដែលពេញប្រៀបក្នុងទ្រូង ទើបបានជាដាច់ចិត្តលើកដៃទៅស្ទាបអង្អែលសរសៃសក់ទន់រលោងរបស់គេ។

ដោយសារពួកយើងជាគ្រិស្តសាសនិក ខ្ញុំអធិដ្ឋានសុំឱ្យគេ ចាប់ពីពេលនេះទៅស្គាល់តែរាត្រីដែលពេញដោយដំណេកស្កប់ស្កល់ និងទិវានានាពេញដោយជោគជ័យនិងស្នាមញញឹម។

«បំភ្លេចរឿងចាស់ៗចោលទៅអាមីន! បំភ្លេចបងម្នាក់នេះ ទុកថាវាបានស្លាប់បាត់ កាលយប់គ្រុនក្តៅមួយនោះ ទុកថាអាម៉ាចមិនបានជួយវា ហើយគ្មានទេ រឿងឈឺចាប់រវាងយើងទាំងបី! លើលោកនេះមានតែឯងហើយនិងអាម៉ាចដែលនៅសល់! ត្រូវថែរក្សាគ្នា!»

មិនបានប៉ុន្មានខ្ញុំឮសំឡេងឡូឡាពីចម្ងាយ នៅច្រកចូលផ្ទះជួល។ អាម៉ាចមកដល់ហើយថែមទាំងស្រែកផ្អើលអស់បន្ទប់ជួលក្បែរខាង ទាំងមាន់រងាវមេឃមិនទាន់ភ្លឺច្បាស់។

សាមីននៅផ្កាប់មុខដេកស្រវឹងក្រោមជាតិពុល។ ខ្ញុំដកដង្ហើមធំចេញទៅជួបវានៅមាត់ច្រក។

«សាមីននៅឯណា?!»

«វាដេកមិនទាន់ភ្ញាក់ទេ!»

ខ្ញុំឆ្លើយធម្មតា អាម៉ាចសម្លក់ខ្ញុំទាំងកំហឹងហើយដើរហួសខ្ញុំទៅកាន់បន្ទប់។ ខ្ញុំក៏ដើរទៅតាមពីព្រោះខ្ញុំបារម្ភ ខ្លាចមានការវាយតប់សាមីនដោយការភាន់ច្រឡំណាមួយ។

«កុំច្រឡំឱ្យសោះ គ្មានស្អីកើតឡើងទាំងអស់!»

ខ្ញុំខំនិយាយតិចៗពីក្រោយខ្នងវា សង្ឃឹមវាស្គាល់ និងនៅចាំចរិតម៉ាត់ណាម៉ាត់ហ្នឹងរបស់ខ្ញុំដឹងអី វាបែរក្រោយមកខាំមាត់គ្រហឹមសម្លុតខ្ញុំ៖

«អត់កើតឡើងទៀត! និយាយស្រួលណាស់»

ខ្ញុំនៅភាំងៗក្រោមភាពឈឺចាប់ដូចឆ្កួតលីលារបស់វា។

ចរិតវាញ៉ៅប៉ប្រែជាមួយស្រីៗខាងក្រៅរាល់ថ្ងៃ លុះជាមួយអាមីន ទំនងវាមិនទុកចិត្តនាង ហើយគិតថា នាងវាយមាយប្រហែលមារយាទវាដែរហើយ បានជាវាខឹងសឹងខាំរបូតអស់ធ្មេញទាំងជួរ។

ខ្ញុំព្យាយាមនិយាយស្រួលៗ បំបាត់កំហឹងវា៖

«អ្អែងឡូឡា អត់ខ្មាសគេទេ? ចុះបើសិនជាអ្នកកាសែតដឹងគេផ្សាយចេញ? អញមិនអីទេ ប៉ុន្តែប្រពន្ធអ្អែងណ៎ា! ប្រាប់ហើយថាវាស្រវឹង វាមកដល់សន្លប់បាត់ភ្លាមហើយ»

ស្រាប់តែម៉ាចដែលដាក់ដៃលើទ្វារផ្ទះខាំមាត់ខមមកខ្ញុំវិញ ទាំងនិយាយតមាត់៖

«ជិតពីរម៉ោងហើយ! អញបាត់ប្រពន្ធអញជិតពីរម៉ោងហើយដឹងនៅ?!»

«ត្រឹមពីរម៉ោងតើ ចំណែកខ្ញុំ ត្រូវនៅជាងពីរឆ្នាំហើយឆ្ងាយពីមនុស្សដែលខ្ញុំស្រលាញ់ ដឹងដែរអត់?»

នេះជាសំឡេងគេនិយាយស្រាលៗស្មើៗ ហើយគេបង្ហាញខ្លួនពីមុខទ្វារដែលរបើកថយក្រោយយឺតៗ។

បើគេមិនរំឭក ខ្ញុំភ្លេចទៅហើយថា ខ្ញុំនៅដោយគ្មានបេះដូងខ្លួនឯងជាប់ទ្រូងជាង៧០០ថ្ងៃមកហើយ។ មនុស្សដែលខ្ញុំស្រលាញ់ បាត់ត្រឹមពីរម៉ោង ប្ដីគេខឹងដល់ម្លឹង ចុះពីរឆ្នាំហើយ ដែលខ្ញុំបានប្រគល់នាងឱ្យទៅវា ម្ដេចវាមិនចេះរក្សាឱកាសមួយនេះ។

សម្ដីនិងកែវភ្នែករបស់សាមីននៅគ្រានោះ នៅតែជាម្ទុលកម្រិតរយដើម ចាក់ឆ្លឹងជាប់នៅក្នុងបេះដូងរបស់ខ្ញុំមកទល់ឥឡូវ ពិសេសពេលដែលខ្ញុំឈរផ្ទឹងទ្រាំមើលប្ដីគេ លើកសែងគេចេញទៅ។

នោះជារាត្រីទៀបភ្លឺ ដែលខ្ញុំមិនអាចបំភ្លេចពេញមួយជីវិតរបស់ខ្ញុំនេះ។ មិនសមថាបន្ទាប់ពីពេលនោះ ខ្ញុំវិលមកជួបគេជាថ្មីគឺនៅលើគ្រែពេទ្យមួយនេះ ជាមួយទឹកមុខបែបនេះ។

«សន្យានឹងបង! ត្រូវតែរឹងមាំ ថែចិត្ត និងព្យាបាលខ្លួនឯងដោយសុទិដ្ឋិនិយមដើម្បីជីវិតតទៅមុខ! ជីវិតមនុស្សម្នាក់ៗ តែងឆ្លងកាត់ការលំបាកតែគ្មានអ្នកណាម្នាក់ព្រមទម្លាក់ដៃចុះចាញ់ងាយៗទេ! គេម្នាក់ៗ គេស្រលាញ់ជីវិតរបស់គេ មិនថាបានឆ្លងកាត់រឿងលំបាកវេទនា ឈឺចាប់ខ្លោចផ្សាអាក្រក់អាក្រីយ៉ាងណា គេនៅតែមានៈចង់បន្តរស់ ដូច្នេះឯងត្រូវតែតស៊ូដើម្បីរស់ ត្រូវរកហេតុផលមួយមកឱ្យខ្លួនឯងរស់តទៅមុខទៀត!»

«ខ្ញុំនឹងតស៊ូដើម្បីរស់! ព្រោះខ្ញុំរកឃើញហេតុផលរបស់ខ្ញុំហើយ! ខ្ញុំនឹងរស់ដើម្បីរង់ចាំពេលវេលាទៅនៅជិតបងម៉ីនវិញដូចដើម! បើស្លាប់បាត់ បានន័យថា នឹងបែកបងម៉ីនជារៀងរហូត!»

មានអារម្មណ៍ថា លើកនេះសាមីនប្លែកៗ នាងនិយាយអ្វីហាក់ខឹងៗខ្ញុំ បកសងមកខ្ញុំវិញជានិច្ច។ ឬមួយថា អាការៈឈឺធ្ងន់នេះពិតជាធ្វើឱ្យនាងផ្លាស់ប្ដូរអត្តចរិត ផ្លាស់ប្ដូរការគិត ចង់រស់ឡើងវិញឬមួយក៏យ៉ាងណា?

អ្វីក៏ដោយចុះ ហោចណាស់នេះជាសញ្ញាវិជ្ជមានមកកាន់ខ្ញុំថា នាងព្រមព្យាបាលខ្លួនឯង លើកលែងតែអ្នកជំងឺយល់ព្រម ចង់បន្តជីវិត ទទួលយកនូវការបរិច្ចាគទៅ ទើបការបរិច្ចាគ និងគម្រោងវះកាត់អាចដំណើរការទៅបាន។

បើសិនជាកម្លាំងចិត្តនាង និងកម្លាំងកាយនាងនៅមិនមានគ្រប់គ្រាន់ ក៏ការវះកាត់នេះនឹងមិនជោគជ័យនោះដែរ។

ខ្ញុំមកលើកម្រាមដៃនាងចេញថ្នមៗ ជាសញ្ញាបង្ហាញថា ទោះបីជាខ្ញុំធំធាត់ឡើងនៅក្នុងតំបន់អនាធិបតេយ្យ មិនមែននៅក្នុងគ្រួសារដែលមានឪពុកម្ដាយគ្រប់គ្រាន់ មកស្ដីឱ្យ ប្រដៅដូចកូនគេឯង  តែខ្ញុំក៏ដឹងពីអ្វីដែលត្រូវ និងអ្វីដែលខុស ជាពិសេសខ្ញុំមិនធ្វើខុសចំពោះមនុស្សដែលខ្ញុំស្រលាញ់នោះទេ។

នាងដូចជាដឹងអំពីការដកថយរបស់ខ្ញុំប៉ុន្តែប្រស្រីទាំងគូ នាងមិនបានដកថយចេញពីកែវភ្នែករបស់ខ្ញុំឡើយគឺនៅតែជំពាក់នៅទីនេះរហូតដល់ខ្ញុំមិនដាច់ចិត្តចេញចោល ខ្សែភ្នែកពេញដោយភាពអង្វរករក៏ដូចជាភាសាសម្ងាត់បញ្ជាក់ច្បាស់លាស់នៅក្នុងការសម្លឹងនោះថា ខ្ញុំអាចដកដៃចេញពីនាងបាន ប៉ុន្តែខ្ញុំមិនអាចដកបេះដូងចេញពីនាងបានជារៀងរហូតនៅក្នុងជាតិនេះ។

ពេលវេលាបែបនេះ បានកន្លងទៅ រយៈពេលជាងមួយសប្ដាហ៍ដែលខ្ញុំត្រូវនៅក្នុងមន្ទីរពេទ្យក្នុងរូបភាពជាអ្នកថែបំប៉នខ្លួនរង់ចាំការវះកាត់ ប៉ុន្តែតាមពិតទៅ មិនមែនបញ្ហាខាងខ្ញុំទេ គឺពេទ្យរង់ចាំឱ្យសុខភាពរបស់នាងអាចដំណើរការបាន។

ល្ងាចនេះក្រោយពីវេជ្ជបណ្ឌិតសុខៈបានប្រាប់ខ្ញុំថា នាងដូចជាមិនចង់ហូបអាហារ ថែមទាំងព្រងើយកន្តើយទៅនឹងដំបូន្មានរបស់ពេទ្យ ខ្ញុំតាំងចិត្តថា នឹងឡើងទៅបបួលនាងដើម្បីដាក់រុញនាងលើរទេះចេញទៅដើរមើលសួនច្បារខាងក្រៅខ្លះ ក៏ជាពេលវេលាដែលខ្ញុំអាចសាកល្បងមើលកម្លាំងចិត្តរបស់នាង ថាតើហេតុអ្វីបានជាកម្លាំងកាយនាងនៅតែទន់ខ្សោយ។

ខ្ញុំឡើងទៅតាមជណ្ដើរដែលថ្ងៃមុនខ្ញុំបានជួបអាម៉ាច ដោយសង្ឃឹមថាថ្ងៃនេះ ខ្ញុំនឹងមិនបាច់ជួបវាក់អើទឹកមុខល្បិចល្បងរបស់វានោះទេ ប៉ុន្តែមិនទាន់ទាំងឈានទៅដល់បន្ទប់របស់នាងផង ខ្ញុំបានសំឡេងទាំងពីរនាក់តឹងសរសៃកដាក់គ្នាពីចម្ងាយ។

ទីនេះជាជាន់សម្រាប់អ្នកជំងឺពិសេស និងករណីកម្រ រង់ចាំទទួលការហោះទៅបរទេស។ល។ បានជាស្ងាត់ព្រោះគ្មានមនុស្ស។ ខ្ញុំយល់ថា ក្រៅពីអាមីន គ្មានអ្នកណានៅត្រាំត្រែងយូរជាងនាងទៀតទេ។ ខ្ញុំចង់ដឹងការពិតពីរឿងនេះ។

ខ្ញុំដើរទើមៗទៅដល់មុខបន្ទប់របស់នាង រៀបនឹងគោះទ្វារចូលទៅថាស្ដីពីរនាក់ប្ដីប្រពន្ធនេះទៅហើយ ប៉ុន្តែ វត្តមានគិលានុបដ្ឋាកម្នាក់បានដើរមកដល់ រៀបតែនឹងផ្តល់ព័ត៌មានមកឱ្យខ្ញុំអំពីវត្តមានប្តីប្រពន្ធគេនៅខាងក្នុង ខ្ញុំក៏បានលើកដៃដាក់ចង្អុលលើមាត់ ជាសញ្ញាបង្ហាញថា «មិនបាច់និយាយទេខ្ញុំដឹង!»

ម្នាក់គិលានុបដ្ឋាកនោះញញឹម ហើយវិលត្រឡប់ទៅបន្ទប់ថ្នាំរបស់នាងវិញ បន្តវេនប្រចាំការរបស់នាង។

ខ្ញុំនៅទីនោះ គឺប្រមាណ២ម៉ែត្រពីទ្វារ តែមិនបាច់ភ័យទេ ខ្ញុំឮសំឡេងខាងក្នុងចេញមកច្បាស់ទែងដោយសារចន្លោះទ្វារដែលមិនបិទជិត។

«ខ្ញុំត្រូវការលែងបងឯង មុនពេលវះកាត់!»

ស្នូរជើងតម្រង់មក ប្រហែលជាម៉ាចឮប្រពន្ធទារលែងអ៊ីចឹង វាខ្លាចមានគេឮ បានជាប្រុងមកបិទទ្វារ។

ខ្ញុំរសៀកខ្លួនទៅបំបាំងនឹងជញ្ជាំងនាផ្លូវទៅកាន់បន្ទប់ថ្នាំ ដឹងអីនាងនិយាយបន្ថែមហាមម៉ាច៖

«កុំបិទ! ខ្ញុំថប់ដង្ហើមណាស់!»

ប្រហែលម៉ាចហួសចិត្តនឹងកិរិយាអាមីនបានជាវាបកក្រោយហើយនិយាយឌឺនាង៖

«លែងបងដើម្បីទៅយកអាម៉ីន?»

«ថាឱ្យចេះគិតផង! បងឯងហៅបងខ្លួនឯងដែលចិញ្ចឹមបងឯង អាៗដាច់សាច់» នាងនិយាយខ្លីៗតាមចរិតរបស់នាង។ សម្ដីនាងបានបំពេញឱ្យខ្ញុំ នូវរសថ្នាំ មកស្អំចិត្តដែលតែងនៅរើឈឺម្ដងម្កាលៗចំពោះមុខចរិតពិសពុល និងរមិលគុណនៃអាម៉ាច។ អាមីន ពីតូចមក មិនមែនជាមនុស្សនិយាយច្រើន នាងមិនពូកែនិយាយនោះទេ ប៉ុន្តែបើនាងនិយាយម្ដងៗ គឺតែងចាក់ចំបេះដូងរបស់យើងតែម្ដងពីព្រោះនាងជាមនុស្សនិយាយត្រង់ និយាយយកជាការ។

ខ្ញុំដែលតែងតែចូលចិត្តស្ដាប់នាងនិយាយ។

«ចង់លែងប្ដីទៅយកប្រុសអារាត់អារាយ គ្មានរឿងងាយស្រួលដល់ម្លឹងទេសាមីន! ត្រូវចេះស្រលាញ់ជីវិតខ្លួនឯង! ត្រៀមរៀបចំខ្លួនវះកាត់ទៅ! បងដឹងថា យើងហ្នឹងធ្វើពុត យើងមិនចង់ញ៉ាំបាយ ហើយ

មិនចង់ទៅវះកាត់ក្រលៀន! ស្ទីលយើងគឺស្ទីលពន្យារពេលច្បាស់ក្រឡែត! ស្អីទៅបំណងពិតប្រាកដរបស់យើង?»

«ខ្ញុំចង់លែងលះ! ឮនៅ? ខ្ញុំប្រាប់ហើយ ថាខ្ញុំចង់លែងលះ!»

«រឿងហ្នឹងមិនបាច់សង្ឃឹមទេ! កុំសង្ឃឹមថាយកលុយទាំងអស់ទៅសោយសុខជាមួយគាត់បាន! គ្មានទេក្នុងជាតិនេះ! បងនឹងឱ្យពេទ្យមកតេស្តឯងម្តងទៀត បើសិនជាសុខភាពឯងល្អ ត្រូវឡើងទៅវះកាត់ភ្លាម!»

«បើខ្ញុំសម្រេចចិត្តថាមិនវះ គឺខ្ញុំមិនវះហើយ!!»

«អត់ស្រលាញ់ជីវិតខ្លួនឯង? ស្រលាញ់គេជាងជីវិតរបស់ខ្លួនទៀត? គាត់សូត្រស្អីខ្លះឱ្យខ្លួនឯងស្តាប់បានជាពង្វក់បានដល់ថ្នាក់មើលប្តីជាសត្រូវ មើលគេអ្នកក្រៅថាជាមាស?? ឱ្យចេះសម្លឹងមើលមនុស្សជិតខ្លួនផង បើបងមិនគិតអូនឯងទេ បងបណ្តោយតាមហ្នឹងទុកឱ្យអូនឯងចុះទៅជួបប៉ាធម៌របស់អូនឯងនៅឋាននរកបាត់ហើយ! ចុងក្រោយទ្រព្យសម្បត្តិទាំងអស់របស់គាត់គង់តែធ្លាក់មកលើបង ដែលជាប្តីពេញច្បាប់! យល់ផងសាមីន! ភ្លឺភ្នែកឡើងវិញ! អ្នកណាជាប្តី អ្នកណាជាសាហាយ!»

ខ្ញុំកត់ពាក្យនេះទុកនឹងអាលដាល់មាត់វាឱ្យបានម្តងទើបអស់ចិត្ត។ ដែលខ្ញុំនៅទ្រាំខាំមាត់ស្តាប់ មិនមែនមកពីខ្លាចវា គឺមកពីខ្ញុំយល់ថាមុននឹងក្រោយវានឹងត្រូវកណ្តាប់ដៃនេះ។

«ទ្រព្យសម្បត្តិដែលខ្ញុំបានមកមុនពេលរៀបការជាមួយបងឯង គឺជារបស់ខ្ញុំ! បើសិនជាខ្ញុំស្លាប់ទៅ ខ្ញុំនឹងប្រគល់ទៅឱ្យសមាគមអ្នកជំងឺទឹកនោមផ្អែមនិងអ្នកខ្សោយក្រលៀនទាំងអស់១០០ភាគរយ! បងឯងនឹងទទួលបាននូវចំណែកណា ដែលខ្ញុំយល់ព្រមឱ្យឬអត់ផងក៏មិនដឹង! »

មនុស្សពីរនាក់ខ្ញុំស្គាល់តាំងពីបាតដៃទទេរកតែបាយបីពេលមិនបានពេលនេះ ចាប់ផ្តើមនិយាយគ្នាស៊ីសាច់ហុតឈាមយកលុយមកដាក់ គងពីលើបេះដូងនិងមនោសញ្ចេតនាវវាងគ្នា។

ពាក្យអសុរោះរបស់ពួកគេ ហួសពីអ្វីដែលខ្ញុំនឹកឃើញ។

ធម្មតាខ្ញុំគួរតែដើរចេញកុំខ្វីស្តាប់រឿងប្តីប្រពន្ធគេ ប៉ុន្តែរឿងមួយដែលខ្ញុំមិនអស់ចិត្តគឺថា ហេតុអីបានជាសាមីន នៅតែមិនគិតពីអាយុជីវិតខ្លួនឯង? ម្ល៉ោះហើយខ្ញុំនៅជំអក់រង់ចាំស្តាប់បន្ត។

«មិននឹកស្មានថា មនុស្សអូនឯង ជាមនុស្សគ្មានបេះដូងដល់ថ្នាក់ហ្នឹងសាមីន! ឯងកើតមក មិនត្រឹមតែមានរូបរាងឈឺផ្តឹកៗ សូម្បីសតិរបស់ឯងក៏ឈឺដែរ! ចិត្តថ្លើមរបស់ឯងក៏មានបញ្ហា ការគិតរបស់ឯងរឹតតែឆ្កួតសុទ្ធ! អាណាវាអ្នកពង្វក់ចិត្តឯងថ្នាក់ហ្នឹង ស្អីទៅបរិច្ចាគលុយឱ្យ Charity? ឯងស្មានថាទៅ

រួចហ្អី? បងឱ្យមេធាវីរកវិធី ថាឯងវង្វេងស្មារតី គឺអាគំនិតហ្នឹងអូនឯងចប់មិនខាន! កុំចង់លេងជាមួយបងតាមអំពើចិត្ត!»

មិនដឹងយ៉ាងមិចរាល់ពាក្យសម្ដីដែលម៉ាចស្ដីឱ្យអាមីន វាដូចជាអាវុធធ្ងន់ៗបុកចំកណ្ដាលមុខខ្ញុំ។

ថ្វីដ្បិតថា មនុស្សស្រីម្នាក់នេះ មានកាយសម្បទាទន់ខ្សោយ នាងរងទារុណកម្មផ្លូវកាយផ្លូវចិត្តពីឪពុកម្ដាយចិញ្ចឹមនាងតាំងពីតូច ធ្វើការធ្ងន់ៗ អង្គុយលាងចានឬបោកខោអាវ សឹងពីព្រឹកទល់យប់មិនដែលក្រោកបាន ការងារជុំវិញខ្លួនរើមិនរួច រហូតដល់នាងមានជំងឺធ្ងន់ធ្ងរផ្នែកតម្រងនោម ប៉ុន្តែសន្ដានចិត្តនាង បេះដូងនាងនៅតែជា នាងសាមីន មិនដែលផ្លាស់ប្ដូរទៅតាមកាលៈទេសៈ ទៅតាមទំហំទឹកលុយ ទៅតាមបរិយាកាសជុំវិញខ្លួន ដូចមនុស្សជុំវិញខ្លួននាងនោះឡើយ។ នាងមិនស័ក្តិសមនឹងពាក្យប្រមាថទាំងអស់ ដែលអាម៉ាចកំពុងប្រមូលមកគប់នាងទេ។

ខ្ញុំខាំមាត់ប្រឆាំងនឹងចិត្តមួយដែលចង់ចូលទៅពាក់កណ្ដាលទំនាស់រវាងប្ដីប្រពន្ធវា តែសម្បជញ្ញៈប្រាប់ឱ្យទ្រាំនៅឆ្ងាយកុំធ្វើជារបាំងនៅចន្លោះកណ្ដាលពួកគេ។

ភ្លាមៗនោះ ខ្ញុំឮអាមីនឆ្លើយតបៈ

«ទោះបីខ្ញុំល្ងង់យ៉ាងណា ឡប់សតិកម្រិតណា ដេកឈឺបែបណា បងឯងកុំស្មានថាខ្ញុំមិនដឹង បងឯងមានប្រពន្ធចុងប៉ុន្មាននាក់នៅខាងក្រៅ! មានស្រីកំណាន់ប៉ុន្មាននាក់ ហើយមកបង្ខំបន្ត រស់នៅជាមួយខ្ញុំដើម្បីអី! ដើម្បីចង់ឈ្នះបងម៉ឺន? បងឯងគ្មានថ្ងៃឈ្នះគាត់ទេ? ចង់ប្រាប់ថា គាត់ជាមនុស្សមានចិត្តស្មោះ ចំណែកបងឯង ទោះកុហកគេបាន បងឯងអាចកុហកទាំងខ្លួនឯងទៀតបាន ប៉ុន្តែបងឯងមិនដែលអាចកុហកខ្ញុំបាននោះទេបងម៉ាច!»

ខ្ញុំញញឹមដោយមិនដឹងខ្លួន។ អារម្មណ៍ខ្ញុំនៅពេលនេះ គឺថាបណ្ដាពាក្យពេចន៍របស់នាង សមណាស់ជាមួយមនុស្សធុនអាម៉ាច។ ចំណែកខ្ញុំ ទោះមិនបានចេះរកនឹកឃើញចេញនូវពាក្យអស់នេះមកជូនវាជាជំនួនមែន តែខ្ញុំយល់ថាសមមុខវាពេកហើយ។

សំឡេងនាងនៅលាន់ឡើងមកទាន់ចិត្តខឹងរបស់ខ្ញុំ.....

«តាំងពីថ្ងៃដែលយើងរៀបការជាមួយគ្នា ខ្ញុំមិនដែលស្រលាញ់បងឯង ប៉ុន្តែខ្ញុំគិតថា ថ្ងៃណាមួយខ្ញុំនឹងស្រលាញ់បងឯង ដូចដែលបងម៉ឺនគាត់បានប្រាប់ខ្ញុំ! កាលហ្នឹងបងឯងប្រាប់ខ្ញុំថាកុំរង់ចាំមនុស្សដែលគេមិនស្រលាញ់យើងមិនស្មោះត្រង់ ហើយយើងត្រូវចេះទុកពេលដែលនៅសល់ឱ្យមនុស្សដែលគេស្រលាញ់យើង ចង់បានភាពស្មោះត្រង់ពីយើង! ប៉ុន្តែពេលវេលាកន្លងផុតទៅ អ្វីសអ្វីខ្មៅ

លាក់មិនដែលជិតទេលោកបណ្ឌិត! ទោះបងឯងទុកខ្ញុំជាមនុស្សល្ងង់ម្នាក់ ខ្ញុំក៏បណ្ដោយតាមហ្នឹងទៅ ប៉ុន្តែល្បិចកលទាំងអស់ដែលបងឯងចោទបងម៉ីន ហើយនិងល្បិចកលទាំងអស់ដែលបងឯងទៅពង្វក់ចិត្តគាត់ ឱ្យព្រមចាកចោលខ្ញុំ ទុកខ្ញុំឱ្យរៀបការជាមួយបងឯង ខ្ញុំឃើញច្បាស់ដូចថ្ងៃ! ការរស់នៅជាមួយគ្នាពីរឆ្នាំជាងមកនេះ មិនត្រឹមតែខ្ញុំមិនអាចបង្កើតចិត្តស្រលាញ់ចំពោះបងឯង ថែមទាំងធ្វើឱ្យខ្ញុំស្អប់ខ្ពើមថែមឡើងៗ!»

អាម៉ាចក្រៅពីខឹងនូវសម្ដីពិតចេញរ៉ាវៗពីមាត់នាង វាចេះយកមកគិតវិភាគ ដឹងកំហុស បែរជានឹកឃើញមកទាញខ្ញុំទៅបន្ទោសបានទៀត៖

«និយាយទៅ និយាយតាមចិត្ត! និយាយតាមដែលអាភាពឆោតល្ងង់ចាញ់ការឆបោក ឆ្លិនភ្នែកពីបងម៉ីន អាបងប្រុសយកខ្លួនប្រាណប្អូនស្រីខ្លួនឯងម្នាក់ហ្នឹង! ការសម្ដែងរបស់គាត់ ប៉ិនណាស់ហើយ! សម្ដែងតួចិត្តល្អ សម្ដែងធ្វើព្រះ! ឯងដឹងន័យពិភពលោកខាងក្រៅប៉ុនណាអ្ហះនាងសាមីន ប្រពន្ធឡប់សតិ! ដេកលើគ្រែផ្ដឹកៗ ដឹងថាមនុស្សមកពីសង្គមឥឡូវ ជាពិសេសពួកមនុស្សគ្មានស្អីទាំងអស់ដូចគាត់ហ្នឹង ក្លាយជាម៉េចដែរ? ដប់ឆ្នាំមកនេះគាត់រស់នៅម៉េច? បើគាត់ល្អមែន គាត់មានឋានៈសង្គមមួយនឹងគេហើយ! មិនមែនដើរតែលតោលធ្វើសន្តិសុខ ធ្វើគ្រូបង្រៀនតាមម៉ោង គ្មានការងារច្បាស់លាស់ គ្មានប្រពន្ធគ្មានកូនអ៊ីចឹងទេ! មានតែឯងម្នាក់ប៉ុណ្ណោះ ដែលចាញ់បោកមនុស្សដូចគាត់!»

ខ្ញុំនៅទ្រេតនឹងជញ្ជាំងស្ដាប់ពាក្យវាយតម្លៃចេញពីមាត់អតីតក្មេងប្រុសដែលខ្ញុំធ្លាប់បានបញ្ចុកបាយ។ ឆន្ទៈមួយដែលខ្ញុំស្គាល់ជាទុនក្នុងជីវិតនេះប្រាប់មកថា កុំឈឺៗៗៗ កុំឈឺទៀតអាម៉ីន យើងមិនរស់ដោយសារ ក្នុងគំនិតទុរយសរបស់វាទេ មនុស្សនេះក្រៅពីរមិលគុណ និងជាសត្វក្រពើមួយក្បាល វាជាកំទេចសង្គមស្ពាយសញ្ញាបត្រពើងខ្លួនកុហកខ្លួនវា។

កុំឱ្យសម្ដីមាក់ងាយរបស់វា មកស្រោចបំផ្លាញភាពមោះមុតរបស់ឯងបាន!

ប៉ុន្តែនៅផ្នែកម្ខាងទៀតនាំបេះដូង ចង្វាក់កំណាចមួយធ្វើឱ្យខ្ញុំព្រិលភ្នែកឡើងៗ ម្រាមដៃស្ដាំខ្ញុំច្របាច់ចូលគ្នា។ ទ្រាំៗៗៗ អាម៉ីន ពាក្យចាស់ពោលថា មនុស្សគ្រប់គ្នា ទទួលខុសត្រូវលើសកម្មភាពខ្លួនឯង មិនមែនសម្ដីអ្នកដទៃទេ  យើងត្រូវទទួលខុសត្រូវចំពោះប្រតិកម្មរបស់យើង ហើយប្រុងប្រយ័ត្នរាល់ពេលឆ្លើយតបជាមួយមនុស្សកម្លៅ។

នៅព្រះវិហារខ្ញុំនិងអាមីនបានអានសៀវភៅជាច្រើន ក្នុងនោះយើងបានរៀនរំងាប់ចិត្តពីមនុស្សដែលមានសន្ដានកម្លៅ មិនចែករំលែក គុណតម្លៃនៃជីវិត មិនចេះស្ងើចអំពើល្អអ្នកដទៃ ថែមទាំងចង្អុលថា

នោះជាការសម្ដែង ហើយទាំងទាមទាររកតម្លៃដោយជាន់ពីលើខ្នងអ្នកដទៃ ជាន់ឈ្លីអំពើល្អរបស់អ្នកដទៃ។

មនុស្សដូចវា រៀនដល់បណ្ឌិតតែគ្មានលទ្ធភាពដើម្បីកំណត់អត្តសញ្ញាណ បុគ្គលណាខ្ពង់ខ្ពស់ ណាតូចទាប គឺវាមើលតែលើទ្រព្យធន។

បើខ្ញុំចង់មានបានរបៀបវានិយាយ អ្នកដែលឈរក្បែរអាមីនពេលនេះ មិនមែនវាសោះឡើយ។

ងាកហើយដើរចេញពីមនុស្សជំពូកវា គឺជាជម្រើសល្អមួយហើយ បើទោះណាជានៅលើលោកនេះសល់តែខ្ញុំនិងវា ក៏មិនចាំបាច់ឱ្យសម្ដីវាមានឥទ្ធិពលអ្វី បានមកលើខ្ញុំដែរ។

សត្វនិងមនុស្សមិនចាំបាច់ពាក់ព័ន្ធគ្នាដល់ជម្រៅបេះដូងក៏បាន!

ពេលខ្ញុំធ្វើមិនឮទាំងខាំមាត់ អាមីនបាននិយាយជំនួសនូវភាសាដួងចិត្តរបស់ខ្ញុំ៖

«បើសិនជាមនុស្សគ្រប់គ្នាក្នុងលោកនេះ សុទ្ធតែជាមនុស្សធុនបងឯង មានន័យថា លើលោកនេះលុយអាចបាំងមុខគ្រប់គ្នា ឋានៈសង្គម សញ្ញាបត្រ ឈ្មោះបណ្ឌិត អាចបិទបាំងភ្នែកពួកគេប៉ុន្តែគ្មានថ្ងៃបាំងខ្ញុំបានទេ! ចេញពីកន្លែងនេះ កុំឱ្យខ្ញុំដង្ហក់ ឬក៏ចុចកណ្ដឹងហៅពេទ្យទាន់!»

ម៉ាចនៅទីទើរទំនងគេដឹងអំពីភាពមានៈរបស់សាមីន។ ខ្ញុំប្រុងថា គេចខ្លួនឱ្យបានមុនពេលដែលវាចាកចេញមក ប៉ុន្តែមិនដឹងយ៉ាងម៉េច ខ្ញុំឃើញអាប្អូនត្បាញអាយរបស់ខ្ញុំ នៅឈរត្រេងត្រាងជិតគ្រែប្រពន្ធដដែល។

ដោយមិនខ្វល់ពីទុក្ខសោកប្រពន្ធដែលស្ដមរីងរៃ ម៉ាចគិតចុះឡើងបានបន្តិច ក៏ដាច់ចិត្តហាសួរខ្សឹបៗ៖

«អ៊ីចឹង បើបងលែងឯង ឯងឱ្យបងប៉ុន្មាន?!»

សាមញ្ញជាទីបំផុត ដែលមនុស្សធ្លាប់សន្យាជាមួយខ្ញុំថា នឹងមើលថែគេអស់មួយជីវិត ចុងក្រោយខ្ញុំឃើញផ្ទាល់នឹងភ្នែក ឮនឹងត្រចៀក។

អាម៉ាចអើយអាម៉េច  បើឯងនៅជាបណ្ឌិតរៀនឆ្លាតជាងក្មេងកំព្រាដទៃ បានអាហារូបករណ៍ទៅប្រទេសអភិវឌ្ឍន៍ ហើយឯងគិតថា ឯងជាមនុស្សអស្ចារ្យ ជាមនុស្សមិនសម្ដែង ជាមនុស្សដែលមានកំណើត មិនអត់កំណើតដូចខ្ញុំ ដូចម្ដេចបានជាឯង មិនអាចរកលុយបានដោយខ្លួនឯង បែរជាមក

តោងទាមលុយមនុស្សស្រី ដែលមិនមែនជារបស់ខ្លួន ម៉េចក៏ឯងគ្មានទំនុកចិត្តចំពោះជីវិតខ្លួនឯង ថាអាចរកបានលុយទាំងនោះដែលមិនពឹងផ្អែកលើអ្នកដទៃ?

ខ្ញុំគិតរួចកាលណា ជាជាងឱ្យអាមីននិយាយជ្រុលពិបាកលេបសម្ដី  ខ្ញុំរុញទ្វារបើកចូលឃ្វាំងចូលក្នុង។

ម៉ាចធ្វើភ្នែកឡិងឡង់សម្លឹងខ្ញុំ។ នេះជារបៀបដែលវាតែងតែសម្លឹងខ្ញុំ នៅរាល់ពេលធ្វើអ្វីខុសម្ដងៗ គឺខ្លាចខឹង ខ្ញុំបោះបង់វាចោល ប៉ុន្តែលើកនេះ ខ្ញុំមិនគិតថា វាខ្លាចត្រូវខ្ញុំបោះបង់ចោលទេ ព្រោះវាជាអ្នកបោះបង់ខ្ញុំចោលមុន។

«មួយរៀលក៏ឯងមិនបានដែរ!» ខ្ញុំនិយាយដោយសម្លឹងជ្រៅៗទៅក្នុងគ្រាប់ភ្នែករបស់វា។